សម្រាប់ដារិទ្ធ ពាក្យបែកគ្នានេះ បានឮមករាប់សិបដងហើយក្នុង៣៤ខែ ដែលសេពគប់គ្នា.....ជិតបីឆ្នាំមកនេះលីតានិយាយរាដដែលៗ សូម្បីតែពេលគ្មានទំនាស់ស្អីជាធំដុំក្តី។

«ថ្ងៃចុងក្រោយនេះ ខ្ញុំសួរមិត្តគេពីរឿងគេបាត់ពីផ្ទះជួល ហើយប្រាប់ថាចេញទៅខេត្តធ្វើការ! មិត្តគេមិនដឹងអីទាំងអស់! មិនដឹងគេទៅជាមួយអ្នកណាទេ តែគេកុហកខ្ញុំ ហើយខឹងខ្ញុំពេលដឹងថាខ្ញុំខលសួរ!»

អ្នកប្រឹក្សានៅស្ងៀមស្តាប់ដោយយកចិត្តទុកដាក់។ គាត់មិនមានប្រតិកម្មអ្វីទេ ដូច្នេះដារិទ្ធផ្តើមរៀបរាប់ទៀត៖

«ខ្ញុំអាចទទួលខុសត្រូវទាំងស្រុង ប្រសិនបើខ្ញុំជាអ្នកមានកំហុស តែ....»

«នាងខឹងដែលរិទ្ធឯងមិនជឿនាង ហើយខលសួរមិត្តភក្តិ!» អ្នកប្រឹក្សានិយាយកាត់។

ដារិទ្ធលេបទឹកមាត់តវ៉ាខ្សឹបៗ៖

«ប្រសិនបើគេមានភាពស្មោះត្រង់ អាហ្នឹងខ្ញុំខុសមែនបង! តែការទុកចិត្តត្រូវបានខូចអស់ហើយ បានជាដល់ដំណាក់កាលខលសួរបញ្ជាក់! វាជារឿងសំខាន់សម្រាប់ម្នាក់ៗ ក្នុងការទទួលខុសត្រូវទាំងស្រុងចំពោះអ្វីដែលបានកើតឡើង ហើយត្រូវយល់ពីរបៀបមិនស្មោះរបស់គេ ដែលប៉ះពាល់ដល់ទឹកចិត្តគ្នា!»

«ដោយសារគេទទួលស្គាល់កំហុស ឬការស្អប់ខ្លួនឯងដែលមិនស្មោះត្រង់បានជាគេទារបែក?!»

«បើគេនៅស្រឡាញ់ គេគួរតែថយមករកវិធីចាប់ផ្តើមកសាងទំនុកចិត្តឡើងវិញ!»

ដារិទ្ធអាយុ២៧ឆ្នាំ ចំណែកលីតាអាយុ២៦ឆ្នាំ។ ពួកគេស្គាល់គ្នាបីឆ្នាំហើយ តែបានកសាងភាពជាដៃគូ រស់នៅជាមួយគ្នាក្រោមដំបូលផ្ទះជួលតែមួយជាងមួយឆ្នាំនេះទេ។

ដំបូងគ្រប់យ៉ាងប្រកបដោយភាពរីករាយ តែក្រោយៗមកដារិទ្ធតែងតែមានអារម្មណ៍ថាលីតាបំពានលើទំនុកចិត្ត។

អ្នកចិត្តសាស្ត្រម្នាក់នេះជារ៉ូ ជាមនុស្សដែលបងប្រុសជីដូនមួយដារិទ្ធណែនាំឱ្យស្គាល់។ គាត់នៅស្ងៀម ព្រោះដារិទ្ធកំពុងនិយាយ៖

«លីតាជាអ្នកផ្ដើមស្នេហានេះមុន! ការងារខ្ញុំមិនទាន់រឹងមាំ ខ្ញុំមិនហ៊ានស្រឡាញ់ស្រីទេ តែគេបានបង្ហាញខ្លួនហើយតាំងចិត្តថាតស៊ូជាមួយគ្នា! តែ....ក្រោយពីយើងមកនៅជាមួយគ្នា គេដូចជាធុញទ្រាន់នឹងការងារផ្ទះ គ្រប់យ៉ាងមិនល្អដូចជាកាលនៅជាសង្សារទេ!»

«ការងារផ្ទះម៉េចមិនជួយធ្វើគ្នា?!»

«ខ្ញុំជួយជានិច្ច តែគេវាយតម្លៃថាខ្ញុំជាមនុស្សគ្មានគោលដៅ ធ្វើការផ្ទះដូចស្រី! និយាយទៅ ភាពរកាំរកូស កើតមានឡើងចាប់ពីពេលមកនៅជាមួយគ្នា! គឺគ្រប់យ៉ាងមិនរំភើបជាមួយគ្នាដូចកាលពីអតីតកាលទេ! នៅបានប្រហែល៣ខែគេសុំបែកគ្នា! ខ្ញុំគិតថា មានការប្រេះឆាក្នុងទំនាក់ទំនងយើង អាចជាការលំបាកដែលត្រូវនៅជាមួយផ្ទះមួយក្រវិច ឬអាចនាងឈឺចាប់ក្នុងការប្រឈមមុខបញ្ហាច្រើនជាងកាលនៅលីវ! ខ្ញុំព្យាយាមធ្វើជាភាគីខុសនិងចាញ់រហូត តែទាំងនេះនៅតែមិនដោះស្រាយបានដដែល! នៅជាមួយគេ ខ្ញុំមិនបានស្មោះត្រង់ចំពោះខ្លួនឯងទេ ពេលខ្លះខ្ញុំសង្ស័យថាគេមានអ្នកផ្សេង តែខ្ញុំធ្វើមិនដឹងមិនឮ!»

«ចុះគេមានអ្នកផ្សេងទេ!» អ្នកប្រឹក្សាសួរ ធ្វើឱ្យដារិទ្ធនៅស្ងៀមឈ្ងោកគិត។

គាត់បន្ត

«ការជឿទុកចិត្តដែលផុយនិងសង្ស័យ អាចធ្វើឱ្យខូចខាតដល់អ្នកគ្រប់គ្នានៅក្នុងទំនាក់ទំនង! ប្រសិនបើខាងស្រីដឹងរឿងនេះគេអាចមានអារម្មណ៍ថា ជាការបំពានធ្ងន់ធ្ងរដែរ!»

«គេតែងខ្លួនប្លែកៗ ហើយទ្រគោះបោះបោកដាក់ខ្ញុំ!» ដារិទ្ធបន្ថែមខ្សោយៗ។

«ការមិននិយាយគ្នាត្រង់ៗ ចិញ្ចឹមចិត្តសង្ស័យក៏អាចធ្វើបាបចិត្តដៃគូរបស់យើងដែរ! កត្តានេះងាយស្រួលបង្កើតនូវភាពអាម៉ាស់ និងការខកចិត្តនៅក្នុងខ្លួនម្នាក់ៗ នឹងមិនជួយស្រោចស្រង់ស្នេហាអ្នកទាំងពីរទេ! ពេលនេះបងមានសំណួរមួយ...»

«បាទបង!»

«យូរប៉ុនណាហើយដែលដារិទ្ធខានបានបង្ហាញការយកចិត្តទុកដាក់ និងការអាណិតអាសូរដល់ដៃគូ?

គេរកនឹក។

«ខ្ញុំឧស្សាហ៍អន់ចិត្តពេក!»

«ក៏ពាក់មុខយក្ខដាក់គ្នា?»

«អត់ទេ តែខ្ញុំមិនសូវល្អកល្អើនដូចមុន!»

«សូម្បីមនុស្សនៅឆ្ងាយពីគ្នា គេនៅតែអាចរក្សា មនោសញ្ចេតនាឱ្យនៅរស់រវើកបាន! ប្អូនត្រូវការ ការប្រឹងប្រែងបន្ថែម មិនមែនកាត់បន្ថយការយកចិត្តទុកដាក់ហើយបន្ថែមការតាមដានលើផ្នែក កំហុសទេ!»

ដារិទ្ធផ្អែកខ្នងគិត។ មិនយូរប៉ុន្មានគេពោលមួយះ

«ឥឡូវនេះគេរើអីវ៉ាន់ចេញអស់ហើយ! ខ្ញុំមកប្រឹក្សានេះគឺមកចង់បានគេវិលមកវិញ!»

បងរ៉ូសម្លឹងអ្នកពិគ្រោះរបស់ខ្លួនពីលើដល់ក្រោមរួចទើបប្រាប់មកគេះ

«ដារិទ្ធ ថយមួយរយៈក៏ល្អ! នៅម្នាក់ឯងសិន គត់សំគាល់សិនថា វាមានសារៈសំខាន់ដែរទេ ដែលគេវិលមកវិញ ឬយើងគ្រាន់តែមិនចង់បែកគ្នា តែតាមពិតយើងអាចរស់ដោយមិនមានគ្នា បាន? អាចទន្ទឹងរង់ចាំពេលវេលាសមរម្យមួយ និងរៀបចំផែនការ ធ្វើឱ្យគេមានអារម្មណ៍ថា ស្នេហានេះនៅតែពិសេសដូចមុន! ជាការពិត ការស្រាវជ្រាវបានបង្ហាញថា ក្នុងទំនាក់ទំនងដែល មិនសូវរឹងមាំ ការសាកល្បងនៅឆ្ងាយពីគ្នា មិនសូវតានតឹងពេក និងរយាលឱ្យយើងមានពេល គិតក្នុងលក្ខខណ្ឌប្រសើរជាង!»

ចេញមកវិញ ដារិទ្ធវិលមកផ្ទះជួល។

គេយល់ថា ការប្រឹក្សានេះមិនជួយអ្វីបានច្រើនទេ។ គេនឹកលីតាខ្លាំងប៉ុនណាគ្មានអ្នកណា ដឹងឡើយ។

«ម៉េចហើយរឿងលីតា?!» បងជីដូនមួយឈៃតមកសួរ។

គេលើកមកចុចតបះ

«នឹកគេណាស់!»

«នឹកប៉ុនណាក៏ដោយ ក៏កុំភ្លេចរឿងសំខាន់ផ្សេងទៀតក្នុងជីវិតរបស់ឯង!»

«គេជារឿងសំខាន់នៃជីវិតខ្ញុំ!»

«ចេញពីផ្ទះមក បំភ្លេចខ្លះទៅ បន្តឡើងវិញរាល់ចំណង់ចំណូលចិត្ត និងចំណាប់អារម្មណ៍របស់ឯង! លេងបាល់ឬមើលកុនជាមួយបង»

«មិនចង់ទៅណាទេ!»

«រៀនសម្របសម្រួលឡើង! សម្របសម្រួលជាមួយជីវិត!»

«កុំសូត្រទ្រឹស្តីដាក់ខ្ញុំ ស្តាប់អីមិនចូលទេ!»

«បងគិតថា ការពន្យល់ត្រង់ណេះគឺសាមញ្ញបំផុត! ពេលនរណាម្នាក់ចង់ចាកចេញពីជីវិតយើង ចង់ទទូចឱ្យគេនៅ ស្នេហានេះវាគ្មានន័យដដែលទេមិនថាពេលនេះឬពេលក្រោយ បើចិត្តគេចង់ទៅគេនៅតែទៅ! ដូច្នេះដើរថយក្រោយមួយជំហានសិន ហើយគិតឡើងវិញម្តងទៀត។»

ដារិទ្ធអានហើយលែងតប។ បងជីដូនមួយគេក៏និយាយមើលតែអ្នកផ្តល់ប្រឹក្សាម្នាក់នោះដែរ តែពួកគេមិនយល់ទេថា លីតាជាមានតម្លៃចំពោះគេជាងអ្វីៗគ្រប់យ៉ាងដែលគេកំពុងតែមាន។

នៅពេលនេះ គេយល់ថា គេបានស្រឡាញ់នាងពិតប្រាកដ ប៉ុន្តែស្នេហាស្ថិតនៅក្នុងខ្លួននាងមិនដឹងថានៅពិតដែរឬអត់ទេ។ ស្នេហាគឺជាអារម្មណ៍ពិសេសមួយ មិនអាចបាត់ទៅដោយរឿងតិចតួចទេ មនុស្សអាចនឹងផ្លាស់ប្តូរ ប៉ុន្តែអារម្មណ៍ស្នេហ៍ដែលចូលទៅនៅក្នុងបេះដូងហើយមិនងាយឡើយ។

Men ជាមិត្តរបស់ដារិទ្ធបានទិញម្ហូបខ្លះមក ព្រោះថ្ងៃនេះជាថ្ងៃសៅរ៍ ណាមួយដារិទ្ធកំពុងខូចចិត្ត។ តែគិតថានៅទីនេះកំដរមិត្តនិងពិគ្រោះគ្នា។

«ព្រឹកមិញឃើញលីតាទិញកាហ្វេ!»

ដារិទ្ធស្ទុះអង្គុយផ្អែកក្បាលគ្រែសួរភ្លាមៗ

«ទៅម្នាក់ឯងឬជាមួយអ្នកណា?!»

Menសម្លឹងដារិទ្ធហើយដកដង្ហើមធំ៖

«ម្នាក់ឯង!»

«ពិតទេ?!»

«ចុម ចង់មានន័យថាម៉េច?» Menចង់ខឹង។

«គេមានអ្នកណាបណ្ដើរទៅទេអី បានជាឯងដកដង្ហើមធំតែមិនហ៊ានប្រាប់គ្នាតាមត្រង់?!»

«ដារិទ្ធ!» Menហៅឈ្មោះពីរម៉ាត់នេះសិន រួចទើបចាប់ផ្ដើមពន្យល់៖

«ក្នុងវិបត្តិស្នេហានេះជឿថា ពួកឯងមិនបានធ្វើអ្វីខុសដាក់គ្នាទេ ត្រូវចេះជឿគ្នា! ប៉ុន្តែពេលដែលរឿងហេតុក្លាយជាបែកដោយមិនសមហេតុផល ពេលអ្វីៗកំពុងដំណើរការល្អមុខតែមានមូលហេតុពិតរបស់វា!»

«គេផ្លាស់ប្ដូរ!» ដារិទ្ធនិយាយខ្លីហើយលឿន។

Menប្រះមកអង្គុយក្បែរហើយពន្យល់ឡើង៖

«បើអីចឹងមែនវាជាការជ្រើសរើសរបស់គេ! បើគេទៅមានសេចក្ដីសុខជាងនៅជាមួយឯង.....!»

«តែបេះដូងខ្ញុំខ្ទេចខ្ទួច!»

«ដឹង! ប៉ុន្តែដោះលែងគេចេញពីបេះដូងរបស់ឯងទៅ បើសិនគេមិនចង់នៅ ក៏កុំបង្ខំ!»

«គ្រប់គ្នាមកនិយាយអ្វីៗស្រួលណាស់! អារម្មណ៍ថាមិនអាចរស់នៅដោយគ្មានគេ មានអ្នកណាយល់ទេ!»

Men នៅស្ងៀម ឯដារិទ្ធិក្រោកទាញខោហើយនិយាយ៖

«ចាំហ្នឹងហើយ ទៅទិញប៊ីយែរ!»

«មិនបាច់ទេខ្ជិលផឹកណាស់! ហើយឯងក៏អ៊ីចឹង ផឹកហ្នឹងអត់ដោះស្រាយអីចេញទេ!»

គេនៅតែរៀបចំខ្លួនចេញទៅទិញ។ មុនទៅ ឆ្លៀតងាកមកប្រាប់៖

«យើងចង់ឱ្យលីតាត្រលប់មកវិញ!»

ថាហើយដើរចាកចេញធ្វើឱ្យMenស្រែកតាមពីក្រោយ ៖

«សំងំផឹកសប្បាយចិត្តឬបំផ្លាញជីវិត? កុំទាន់គិតដល់រឿងគេមកវិញ! ការងារស្អែកថ្ងៃចន្ទមិនដឹងម៉េចផង!»

នៅតូបលក់ភេសជ្ជៈគេឃើញសារអ្នកផ្ដល់ប្រឹក្សាឈ្មោះរ៉ូផ្ញើមក៖

«គោលដៅរបស់ដារិទ្ធ គឺត្រូវខំឡើង ដើម្បីរស់សប្បាយចិត្ត និងធ្វើគ្រប់យ៉ាងបានល្អដោយមានឬគ្មានលីតា! រឹងមាំឡើង!»

ដារិទ្ធរអ៊ូរទាំព្រោះមួហ្មង៖

«សូត្រទ្រឹស្តី មិនយល់អារម្មណ៍ពិតៗរបស់អ្នកប្រឈមមែនទែនទេលោកគ្រូ!»

នៅទីនេះវិញ បងជីដូនមួយរបស់គេឈ្មោះរិន កំពុងណាត់ជួបជាមួយលីតា។

«ការបែកគ្នារបស់ឯងនិងដារិទ្ធធ្វើឱ្យពួកយើងស្រឡាំងកាំង! វាស្រឡាញ់លីតាឯងណាស់!»

«បងកុំបាច់មកនិយាយ ខ្ញុំសម្រេចចិត្តរួចហើយ!» លីតានិយាយឡើង។

«តែដារិទ្ធនៅមិនទាន់ទទួលយកបាននៅឡើយ!»

«ប៉ុន្តែ.....ចុះបងឱ្យខ្ញុំធ្វើម៉េច? អូខេ ប្រហែលជាគាត់ល្អស្មោះសម្រាប់ភ្នែកគ្រប់គ្នា គាត់ទិញអំណោយឱ្យខ្ញុំ ធ្វើការមានប្រាក់ខែ ចេះជួយការងារផ្ទះ ប៉ុន្តែនៅតែចរិតគាត់ ពិបាករស់នៅជាមួយ! ខ្ញុំបានព្យាយាមហើយបង តែយើងមិនអាចបង្ខំបានទេ គ្រាន់តែមុនហើយនិងក្រោយ!!»

«លីតា ធ្វើជាទៅខេត្តនិងកុហកដារិទ្ធដើម្បីឱ្យវាតាមទាន់ហើយបានលេសលែងទុកចិត្តគ្នា កាត់ទំនាក់ទំនង?!»

«បងគិតអ៊ីចឹងក៏បាន!»

«ម៉េចក៏មិននិយាយគ្នា? យ៉ាងណាក៏មិនគួរព្យាយាមក្លែងរឿងដែរព្រោះធ្វើ ដូច្នេះឲ្យលីតាធ្វើជាមនុស្សអាក្រក់និងកុហកមិនស្មោះ?»

លីតាលេបទឹកមួយកែវដាច់អស់ហើយ ហើយទើបនាងលើកនិយាយឡើង៖

«ខ្ញុំមិនខ្លាចការវិនិច្ឆ័យពីអ្នកដទៃអីទេ! គ្មាននរណាម្នាក់ចង់ក្លាយជាមនុស្សស្រីដែលធ្លាប់បរាជ័យស្នេហាកណ្តាលផ្លូវដែរបង!»

នាងចាប់ផ្តើមយំ។

រិនបានឱកាសនិយាយសួរនាំ៖

«បើនៅអារម្មណ៍ឈឺចាប់ខ្លះ មានកំហឹង មានទឹកភ្នែក អាចថានៅស្រឡាញ់គ្នា!»

«ចា៎ ខ្ញុំនៅស្រឡាញ់! ខ្ញុំកំពុងផ្ដាច់! ខ្ញុំនឹងបំភ្លេចគាត់ចោលបាននៅពេលខាងមុខ!»

«ធ្វើអ៊ីចឹងធ្វើអី?!»

ទោះបីការព័ត៌មានលម្អិតអំពីរឿងរ៉ាវនឹងធ្វើឱ្យនាងកាន់តែឈឺចាប់ តែនាងក៏ចង់ចែកច្បាស់ថាអ្វីៗបានចប់សព្វគ្រប់ដោយដើរតាមគំនិតនិងការគិតមិនដើរតាមបេះដូង។

លីតាផ្ដល់ចម្លើយខ្លីៗពីមូលហេតុពិតដល់វិនៈ

«ពីមុន ខ្ញុំគិតថាបើយើងស្រឡាញ់គ្នាយើងនឹងនៅជាមួយគ្នាបានហើយ! តែតាមពិតមិនមែនទេ ពេលណាដែលយើងដឹងចរិតគ្នាច្បាស់លាស់ហើយបន្តត្រដាបត្រដួសនៅទាំងបង្ខំវាគ្រាន់តែខ្ជះខ្ជាយពេលវេលាបន្ថែមព្រោះមុនក្រោយគង់តែ......»

«ទុកឱកាសឱ្យគ្នាម្ដងទៀតនិយាយគ្នាត្រង់ៗទៅ!»

«គ្មានឱកាសទេបង! មិនមានវិធីដែលអាចត្រលប់ជានាជាមួយគ្នាវិញទេ! វាជាចរិតមនុស្ស ការយល់ឃើញរបស់មនុស្សដែលមិនអាចប្ដូរបាន! គាត់ជាមនុស្សដែលមិនមានសុវត្ថិភាពជាមួយសូម្បីតែខ្លួនគាត់!»

«អត់យល់ទេ! បងមិនយល់ទេលីតា!» វិនសួរបញ្ជាក់ត្រង់ណោះដោយយកចិត្តទុកដាក់។

«គឺគាត់អាចមានអារម្មណ៍ខឹងឬថប់បារម្ភ និងបាក់ទឹកចិត្ត ប្រចណ្ឌសង្ស័យភ្លាមៗ សូម្បីតែខ្ញុំភ្លេចមកនិយាយផ្អែមៗល្ហែមដាក់គាត់ ឬស្លៀកពាក់ស្អាតបន្តិចតុបតែងបន្តិច! ការប្រចណ្ឌបន្តិចបន្តួចអាចថា ok ក្នុងទំនាក់ទំនង ទោះជាយ៉ាងណាក៏ដោយ ការច្រណែនច្រើនលើសលប់ និងគួរឱ្យខ្លាចបានកើនឡើងពីមួយថ្ងៃទៅមួយ ជាពិសេសអាកប្បកិរិយាដ៏គ្រោះថ្នាក់របស់គាត់ ដូចជាការតាមឆែកលើបណ្ដាញទំនាក់ទំនងរបស់ខ្ញុំ ឆែកទូរសព្ទនិងជិះតាមឃ្លាំខ្ញុំ!»

«ដល់ម្លឹង?!»

«មិនមែនមិនត្រូវបានដោះស្រាយទេ! ការច្រណែនប្រចណ្ឌទាំងនេះគាត់ថាមកពីស្រឡាញ់តែខ្ញុំខំជួយគាត់ណាស់ ដើម្បីយកឈ្នះអារម្មណ៍ទាំងនោះតែ គាត់ជាមនុស្សប្រៀបធៀប មានភាពតានតឹង មិនសមហេតុផលបើគ្រាន់តែមានអ្នករួមការងារថ្មីម្នាក់រាងសង្ហាទើបនឹងចូលធ្វើការ

គាត់ចាប់ផ្ដើមប្រមាញ់តាមដានគេ? វាអាចបំផ្លាញទំនាក់ទំនងការងារខ្ញុំយ៉ាងធ្ងន់ធ្ងរ! មនុស្សនៅកន្លែងធ្វើការខ្ញុំខ្លះ សឹងលែងហ៊ានបាយជាមួយខ្ញុំ!»

«ហេតុអីលីតាចាំបាច់និយាយពាក្យបែកគ្នាដដែលៗ! ពាក្យនេះធ្វើឱ្យមនុស្សជាក៏ក្លាយជាខូចចិត្តដែរ!»

លីតាឮហើយតវ៉ាភ្លាមៈ

«ខ្ញុំធ្លាប់និយាយម្ដងគត់បងពេលគាត់ឆែកទូរសព្ទខ្ញុំមើល! ចំណែកពេលក្រោយនេះ ខ្ញុំបែកតែម្ដង គឺមិននិយាយទេ!»

ចេញពីនោះ វិនពិបាកចិត្តខ្លាំង។ គេស្គាក់ជួបជាមួយគ្រូប្រឹក្សារ៉ូដែលជាមិត្តភក្តិ។

រ៉ូព្រមទទួលស្គាល់ថា ដារិទ្ធមានចរិតច្រណែនប្រចណ្ឌ តែមិនធម្មតាដូចគេឯងទេ។

«ពាក្យបែកដដែលៗរបស់លីតា អាចជាពាក្យផ្ទួនក្នុងអារម្មណ៍ដារិទ្ធ ដែលរក្សាទុកសម្រាប់ខ្លួនឯង! មនុស្សមានបញ្ហានេះ អាចនឹងរក្សាទុកពាក្យអវិជ្ជមានចងចាំបានយូរណាស់! ចំណែករឿងប្រចណ្ឌ បើម្ដងម្កាល គឺជាការដាស់តឿនគូស្នេហ៍កុំឲ្យលើសចំពោះគ្នាទៅវិញទៅមក និងជួយឱ្យស្នេហាកាន់តែរឹងមាំ ក្នុងកម្រិតតូចមួយដែលអាចគ្រប់គ្រងបាន! រីឯបើការប្រចណ្ឌអាចដល់ថ្នាក់បង្កើតជាកម្លាំងអវិជ្ជមានក្នុងទំនាក់ទំនង បង្ករួមភេទ ឈ្លោះទាស់ទែង គឺការគំរាមកំហែងដែលបង្កើតអសន្តិសុខផ្លូវចិត្ត ពិសេសមនុស្សស្រី ដែលជាសញ្ញាព្រមាននៃទំនាក់ទំនងមួយ បំពានសិទ្ធិគ្នា!»

វិនក្រពាត់ដៃពិបាកចិត្ត។ គេនៅស្ងៀមស្ដាប់ ឯរ៉ូក៏ពន្យល់ទៀតៈ

«នៅទីបំផុត មនុស្សប្រចណ្ឌបែបអសន្តិសុខ តែងតែមានបំណងចង់គ្រប់គ្រងលើដៃគូរបស់ពួកគេនៅគ្រប់កាលៈទេសៈ! ពួកគេបំពានសិទ្ធិឯកជន គំរាមកំហែងដោយពាក្យសំដី និងឈានដល់អំពើហិង្សា ដើម្បីរក្សាអំណាចគ្រប់គ្រង និងបន្ទូរបន្ថយ ឬបិទបាំងអារម្មណ៍ប្រចណ្ឌរបស់គេ។»

«ម៉េចបានប្អូនខ្ញុំអាចមានជំងឺនេះ?!»

«កើតចេញពីការភ័យខ្លាចថាត្រូវបោះបង់ចោល និងការព្រួយបារម្ភអំពីការមិនស្រឡាញ់ពិតប្រាកដ។ អាចគាត់ស្រមៃឬធ្លាប់ឃើញអ្នកណាធ្វើបែបនេះ ឬធ្លាប់មានអតីតកាល!»

«ឥឡូវយើងត្រូវធ្វើម៉េច?!»

«រកវិធីឱ្យគេសម្រាកឱ្យបានច្រើននិងសម្អាតរឿងចាស់ឱ្យបានស្អាត បានន័យថាកន្លែងអនុស្សាវរីយ៍កុំសូវទៅ ! គេចមុខគ្នាបានយូរបន្តិចល្អ! ត្រូវដឹងថា អ្នកដែលមិនព្រមទទួលយកការបាត់បង់កំពុងមានអារម្មណ៍ឈឺចាប់ខ្លាំង និងមានអារម្មណ៍ចម្រុះទាំងល្អនិងអាក្រក់ និងគិតថាគេបានជួបស្នេហាមិនពិត! មធ្យោបាយតែមួយគត់ដែលល្អ គឺមិនមែនស្វែងរកស្នេហាពិតមួយផ្សេងទៀតមកជំនួសទេ តែព្យាបាលគេឱ្យជា! គេត្រូវការការផ្ដល់ប្រឹក្សាញឹកញាប់នឹងលេបថ្នាំរំងាប់ចិត្ត!»

ដោយសារវិនសន្មត់ថា រ៉ូជាមនុស្សល្អមានបទពិសោធ ដ្បិតដំបូន្មាននេះមានខ្លះពិបាកទទួលយកតែគេនៅតែមិនចង់ឱ្យគ្រប់យ៉ាងធ្ងន់ធ្ងរជាងនេះឡើយ។

គេបានណាត់ប្អូននិងMenចេញមក។ បីអ្នកគេរកកន្លែងបរិយាកាសល្អ ស្ដាប់ភ្លេងស្រាលៗ និងជជែក។

«អ្នកទាំងពីរម៉េចក៏គ្រាន់បើជាងខ្ញុំ!»

ដារិទ្ធផ្ដើមដោយនិយាយបែបនេះ។ Men មិនមាត់ ទុកឱ្យវិនជាអ្នកតបៈ

«ធម្មតាទេដារិទ្ធ! តែងតែមានផ្នែកដែលមិនគួរជាទីពេញចិត្តនៅក្នុងជីវិតរបស់មនុស្សយើង។ ជួនកាល វាមកពីយើងរំពឹងទុកហួសហេតុ!»

«រំពឹងហួសហេតុអី? ខ្ញុំមានចង់បានអីហួសហេតុ? ខ្ញុំគ្រាន់តែចង់បានគេ លីតា! ខ្ញុំមិនលោភដូចអ្នកដទៃឯណា ខ្ញុំមិនលោភដូចពួកគេទាំងនោះមានសង្សារមុខក្រោយ ខ្ញុំមានតែលីតាម្នាក់ប៉ុណ្ណឹង»

វិនដឹងថារោគសញ្ញានៃជំងឺរបស់ដារិទ្ធ គឺការខឹងសម្បារ ការបាក់ទឹកចិត្ត អារម្មណ៍យល់ថាខ្លួនឯងមិនសក្តិសមនឹងអ្វីមួយបានជាទៅប្រៀបធៀបខ្លួនឯង សូម្បីតែជាមួយមិត្តរួមការងារថ្មីរបស់លីតា។

គេនិយាយពន្យល់៖

«ទាំងអស់នេះគឺដោយសារតែផ្នត់គំនិតរបស់ឯងដារិទ្ធ! អារម្មណ៍សប្បាយចិត្តឬមិនសប្បាយចិត្ត គ្មានអ្នកណាចៀសរួចទេ ប៉ុន្តែយើងអាចគ្រប់គ្រងវាបាន គួរតែចេះគ្រប់គ្រងវាសិន! អ្នកដែលរស់នៅជាមួយឯងគេចប់ដង្ហើមណាស់ជាមួយគំនិតបែបនេះ! ប្រភេទដែលយកក្រេឌីតថាខ្លួនឯងត្រូវហើយគេផ្សេងខុស! ហេតុអ្វីត្រូវអស់សង្ឃឹម ហើយប្រៀបធៀបខ្លួនឯងជាមួយអ្នកណា?»

មិននឹកស្មាន ថាដារិទ្ធលែងតបតហើយផ្ដើមផឹកស្រា។ បានបន្តិចគេរអ៊ូរទាំឡើង៖

«ខ្ញុំមិនស្អាត មិនពូកែដូចពួកដែលធ្វើការនៅជុំវិញគេ!»

នេះជាសំឡេងរំខានខាងក្នុងខ្លួនគ្រប់មនុស្សមានជំងឺច្រណែន សំឡេងនោះតែងដុតគេជាសម្ងាត់ថា គេអន់ មិនស្អាត មិនពិសេស ហើយយកខ្លួនគេទៅធៀបនឹងម្នាក់ទៀតសូម្បីអ្នកនោះមិនធ្លាប់ស្គាល់គេផងក៏មាន។

រ៉ូបានពន្យល់រិនពីរឿងនេះ។ បញ្ហាដ៏សំខាន់ គឺជាទម្រង់នៃការនិយាយប្រាប់ដោយខ្លួនឯងដោយគំនិតនិងរូបភាពអវិជ្ជមាន។ ជំងឺនេះវាបន្តកើតមានឡើងនូវគំនិត និងអារម្មណ៍ដែលបំផ្លិចបំផ្លាញ ជំរុញឱ្យយើងមួយថ្ងៃៗ ដេកឱបខ្លួន នឹកប្រៀបធៀប វាយតម្លៃ និងវិនិច្ឆ័យខ្លួនយើងថាជាជនរងគ្រោះ។

«បងនឹងនាំឯងទៅព្យាបាល!»

ដារិទ្ធសើច៖

«មានពេទ្យព្យាបាលរោគខូចចិត្តដែរ?!»

«ឯងមិនខូចចិត្តទេតែឯងប្រើអារម្មណ៍ ហើយឯងជឿលើអារម្មណ៍ដែលមិនល្អរហូតដល់វាបញ្ឆោឯងបាន!»

«កោតណាស់បងរិន! ខ្ញុំរងការផិតក្បត់.....ខ្ញុំឈឺចាប់វាធម្មតាទេ!»

«អ្នកណាផិតក្បត់ឯង?!»

ដារិទ្ធនៅស្ងៀមវិញព្រោះឆ្លើយមិនបាន។

រិនក៏និយាយផ្ទាន់៖

«អារម្មណ៍ឯង! សំឡេងខាងក្នុងគំនិតអវិជ្ជមានគំនិតរិះគន់គំនិតសង្ស័យ គំនិតមិនទុកចិត្ត របស់ឯងប្រាប់ឯងថា លីតាមានថ្មី? តែឯងរកអ្នកថ្មីនោះមិនឃើញទេមែនទេ? ឯងដើរចង្អុលសង្ស័យគ្រប់គ្នានៅកន្លែងធ្វើការរបស់គេ? សូម្បីតែគេទៅខេត្តឯងមិនតែសួរគេឯងទៅសួរពួកម៉ាកគេ? នេះជាអារម្មណ៍អវិជ្ជមានកុំថាលីតា សូម្បីបងក៏នៅជាមួយឯងមិនបានដែរ! វាធ្វើឱ្យអ្នកដែលនៅជាមួយយើងហត់ចិត្ត! គេហត់នឹងពន្យល់ ហត់នឹងការតាមឃ្លាំរបស់យើង! ឯងត្រូវព្យាបាលចេញ!»

«ហេតុអ្វីបានជាគេចេញពីធ្វើការយឺត?» ដារិទ្ធទ្រោបក្បាលរអ៊ូ។

«ហេតុអ្វីបានជាទូរសព្ទចាំបាច់មាន Password?»

«គេកំពុងធ្វើអ្វីពេលនៅឆ្ងាយពីខ្ញុំ?»

«គេតុបតែងខ្លួនស្អាតៗធ្វើអីបើមានខ្ញុំហើយ?!»

វិន និង Men មើលមុខគ្នា។

អ្នកនិពន្ធសរសេររឿងខ្លីមួយនេះឡើង ជាការក្រើនរំឭកអ្នកអានឱ្យចេះថែទាំអារម្មណ៍វិជ្ជមានរបស់ខ្លួនឯង។ អារម្មណ៍អវិជ្ជមាន នឹងបំផ្លាញយើងគ្រប់យ៉ាងបាន សូម្បីតែមនុស្សដែលស្រឡាញ់យើងបំផុតក៏មិនអាចទទួលយកអារម្មណ៍នេះបានដែរ។

ត្រូវដឹងពីអ្វីទៅជាមូលហេតុដែលបង្កឡើងនូវគំនិតអវិជ្ជមាន។ វាលូតលាស់លឿនណាស់នៅក្នុងស្ថានភាពខ្លះ ដូចជាឃើញគេមានជោគជ័យផ្នែកហិរញ្ញវត្ថុជាងយើង ឃើញដៃគូយើងល្អជាង។ល។ អារម្មណ៍អវិជ្ជមានទាំងនេះ ធ្វើឱ្យយើងមានអារម្មណ៍ថា ខ្លួនឯងមិនសំខាន់ អសមត្ថភាព មិនជោគជ័យ មានសម្ពាធតឹងតែង និងអស់សង្ឃឹម។

ត្រូវចេះបែងចែករវាងការពិត និងអារម្មណ៍ដែលកើតឡើងនៅពេលដែលយើងឆ្លុះបញ្ចាំងពីជីវិតរបស់យើង។ ពេលយើងមានអារម្មណ៍ច្រណែនប្រចណ្ឌ រកវិធីដើម្បីត្រលប់មកខ្លួនយើងវិញ ហើយបន្ទន់ចិត្តគិតអំពីធម៌ឬ អ្វីដែលអាចទៅរួចក្នុងការទទួលយក និងទទួលស្គាល់ថានោះគ្រាន់តែជាគំនិតអវិជ្ជមានរបស់យើង ដោយការក្រោកដើរឬដកដង្ហើមវែងៗ ស្ងប់ស្ងាត់ បើកចំហចិត្ត។

កុំធ្វើសកម្មភាព ពេលមានសំឡេងអវិជ្ជមានបញ្ចេះមកពីខាងក្នុងចិត្ត ព្រោះភាគច្រើន ជំរុញយើងឱ្យធ្លាក់ចូលទៅក្នុងស្ថានភាពនៃការបោះបង់ លែងជឿ ឬធ្វើអ្វីដែលបំផ្លិចបំផ្លាញខ្លួនឯង បំផ្ទុះកំហឹងរាលដាល ឬដាក់ទោសទៅលើអ្នកនៅក្បែរយើង។

ចុងក្រោយយើងនឹងបាត់បង់ដោយពាក្យថា«លា»។ គ្មានគំនិតអវិជ្ជមានណាមួយនាំមកនូវសុភមង្គលទេ។